ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០២ សហវ.សរ.ថវក

# សារាចរ
# ស្ដីពី
# ប្រតិទិនសម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥

អនុលោមតាមមាត្រា ៥១ នៃច្បាប់ស្ដីពីហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមដាក់ឱ្យអនុវត្តប្រតិទិនសម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ ដូចខាងក្រោម៖

ក-ដំណាក់កាលនៃការរៀបចំផែនការកម្រិតយុទ្ធសាស្ត្រ

**-ចាប់ពីសប្ដាហ៍ទី ១ នៃខែ កុម្ភៈ ឆ្នាំ ២០២៤ ដល់សប្ដាហ៍ទី ១ នៃខែ មេសា ឆ្នាំ ២០២៤**, ក្រុមការងារជំនាញនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចាប់ផ្ដើមដំណើរការពិគ្រោះយោបល់កម្រិតបច្ចេកទេសជាមួយជំនាញរបស់ក្រុមការងារថវិកានៃក្រសួង-ស្ថាប័នពាក់ព័ន្ធ តាមការចាំបាច់ ដើម្បីប្រមូលធាតុចូលសំខាន់ៗ ដូចជា គោលនយោបាយថ្មី (New Policy) និង កត្តាជំរុញតម្រូវការ (Demand Driver) ជាដើម សម្រាប់ជាមូលដ្ឋាននៃការរៀបចំក្របខ័ណ្ឌថវិការយៈពេលមធ្យម ជាពិសេស សម្រាប់ការដាក់ចេញ **ពិតានចំណាយគោល** សម្រាប់ក្រសួង-ស្ថាប័ន ឱ្យមានភាពជាក់ស្ដែង និងគ្រប់ជ្រុងជ្រោយ។ នៅក្នុងអំឡុងពេលនេះដែរ ក្រុមការងារជំនាញនៃអគ្គនាយកដ្ឋានថវិកា ចាប់ផ្ដើមដំណើរការពិភាក្សាបឋម លើរចនាសម្ព័ន្ធកម្មវិធី និងការកំណត់សូចនាករសមិទ្ធកម្មសម្រាប់ថវិកាឆ្នាំ ២០២៥ នៅកម្រិតកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ក្នុងគោលដៅដើម្បីបង្កើនគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាសមិទ្ធកម្មរបស់ក្រសួង-ស្ថាប័ន។

**-នៅសប្ដាហ៍ទី ៤ នៃខែ មេសា ឆ្នាំ ២០២៤**, ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧ ត្រូវបានពិនិត្យ និងសម្រេចដោយរាជរដ្ឋាភិបាល។

**-នៅដើមខែ ឧសភា ឆ្នាំ ២០២៤**, ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧ និងសារាចរស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៥-២០២៧ និងការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ ត្រូវបានដាក់ជូន **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** ពិនិត្យ និងសម្រេច។

ខ-ដំណាក់កាលនៃការរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំ

ផ្អែកតាមគោលការណ៍ណែនាំដែលត្រូវបានកំណត់ក្នុងសារាចរស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៥-២០២៧ និងការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥, គ្រប់ក្រសួង-ស្ថាប័ន ត្រូវរៀបចំ**ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៥-២០២៧** និង **គម្រោងថវិកាលម្អិតឆ្នាំ ២០២៥** ព្រមទាំងត្រូវភ្ជាប់មកជាមួយនូវ**គម្រោងសមិទ្ធកម្មប្រចាំឆ្នាំ ២០២៥** សម្រាប់ដំណើរការកិច្ចប្រជុំពិនិត្យ ពិភាក្សា និងចរចាថវិកា ដែលនឹងត្រូវធ្វើឡើងជា **២ កម្រិត** ដូចខាងក្រោម៖

(ទី១)-**កិច្ចប្រជុំកម្រិតបច្ចេកទេស៖** ការប្រជុំពិភាក្សាគម្រោងថវិការបស់គ្រប់ក្រសួង-ស្ថាប័ន នឹងត្រូវធ្វើជាបន្តបន្ទាប់នៅក្នុងខែ កក្កដា ដោយចាប់ផ្ដើមពី**ថ្ងៃទី ១ ខែ កក្កដា** ឆ្នាំ ២០២៤ និង

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

(ទី២)-**កិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំ៖** ការប្រជុំពិភាក្សាគម្រោងថវិការបស់គ្រប់ក្រសួង-ស្ថាប័ន នឹងត្រូវដំណើរការជាបន្តបន្ទាប់នៅក្នុងខែ សីហា ដោយចាប់ផ្ដើមពី**ថ្ងៃទី ១ ខែ សីហា** ឆ្នាំ ២០២៤។

**គ-ដំណាក់កាលនៃការអនុម័តសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ**

សេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ នឹងត្រូវដំណើរការអនុម័តតាមប្រតិទិនដូចខាងក្រោម៖

-**ក្នុងអំឡុងពាក់កណ្ដាលខែ តុលា ឆ្នាំ ២០២៤**, សេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ ត្រូវបានដាក់ឆ្លងក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដើម្បីធ្វើការពិនិត្យ និងសម្រេច។

-**យ៉ាងយូរនៅសប្ដាហ៍ទី ៤ នៃខែ តុលា ឆ្នាំ ២០២៤**, សេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ និងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀត ត្រូវបានបញ្ជូនទៅដល់**រដ្ឋសភា** ដើម្បីធ្វើការពិនិត្យ និងអនុម័ត។

-**យ៉ាងយូរនៅសប្ដាហ៍ទី ១ នៃខែ ធ្នូ ឆ្នាំ ២០២៤**, សេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ និងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀត ត្រូវបានបញ្ជូនទៅដល់**ព្រឹទ្ធសភា** ដើម្បីពិនិត្យ ហើយឱ្យយោបល់ **មុនថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០២៤**។

-**យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤**, ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម ព្រមទាំងបែបបទអនុវត្តត្រូវបានរៀបចំចប់សព្វគ្រប់។

ទទួលបានសារាចរនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្សព្វផ្សាយ អនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ... ខែ ... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- អគ្គនាយកដ្ឋានថវិកា
- គ្រឹះស្ថានសាធារណៈរដ្ឋបាល
- សាលារាជធានី ខេត្ត
- មន្ទីរជំនាញរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ